# ផ្ទះពិតប្រាកដរបស់យើង

ធម្មទេសនាទៅកាន់ឧបាសកចាស់ជរាមួយរូបដែលជិតទៅកាន់សុគតិភព



ព្រះអាចារ្យ ឆា

## **សូមអនុមោទនាធម្មទាន!**

## **សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង!

## **ចិរំ តិដ្ឋតុ ពុទ្ធសាសនំ**

សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក

សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព

ព្រះសក្យមុនិសម្ពុទ្ធទ្រង់ត្រាស់ថា នត្ថិ សន្តិ បរំ សុខំ

ពុំមានសេចក្តីសុខដទៃ ក្រៅពីសេចក្តីស្ងប់ឡើយ។

- សូមឧទ្ទិសផលានិសង្សនៃធម្មទានទាំងនេះ ថ្វាយ ប្រគេន ជូនចំពោះបុព្វការីជនរបស់យើងខ្ញុំទាំងឡាយ។
- សូមឲ្យកូនចៅទាំងអស់គ្នា មានប្រាជ្ញាភ្លឺថ្លា សម្រេចមគ្គផលបរមសុខ គោលគឺ **ព្រះនិព្វាន**។

S̊MISIS

# ផ្ទះពិតប្រាកដរបស់យើង

ព្រះអាចារ្យ ឆា

ធម្មទេសនាទៅកាន់ឧបាសកចាស់ជរាមួយរូបដែលជិតទៅកាន់សុគតិភព

# ព្រះអាចារ្យ ឆា

ព្រះអាចារ្យ **ឆា** មានកំណើតក្នុងគ្រួសារធំ ហើយសុខសាន្តនៅភូមិជនបទមួយផ្នែកឦសាននៃប្រទេសថៃ។ កាលនៅក្មេង ព្រះអង្គបានបួសជាសាមណេរ ហើយលុះដល់បានអាយុ ២១ ឆ្នាំ ក៏បានទទួលឧបសម្បទាជាភិក្ខុ។ ក្នុងឋានៈជាយុវភិក្ខុ ព្រះអង្គបានសិក្សាគោលសំខាន់ៗខ្លះនៃព្រះធម៌ ព្រះវិន័យ និងគម្ពីរផ្សេងៗ។ ក្រោយមកព្រះអង្គបានប្រតិបត្តិកម្មដ្ឋាន នៅក្រោមឱវាទនៃព្រះគ្រូអាចារ្យល្បីល្បាញជាច្រើន ក្នុងប្រពៃណីសមណធុតង្គ។ ព្រះអង្គបាននិមន្តត្រាច់ចរច្រប់ជាច្រើនឆ្នាំ តាមប្រពៃណីសមណភិក្ខុ, សឹងក្នុងព្រៃ រូងភ្នំ និងទីស្មសាន ហើយបានសម្នាក់នៅមួយរយៈពេលយ៉ាងខ្លីតែភ្លឺស្វាងជាមួយព្រះអាចារ្យមុន ដែលជាព្រះគ្រូអាចារ្យកម្មដ្ឋានមួយអង្គយ៉ាងល្បីល្បាញ និងជាទីគោរពបំផុត ក្នុងចំណោមព្រះអាចារ្យធំៗ នាសតវត្សនេះ។ ក្រោយពីបានធ្វើដំណើរ និងប្រតិបត្តិធម៌ជាច្រើនឆ្នាំមក គេបាននិមន្តព្រះអង្គឲ្យមកតាំងទីលំនៅនៅក្នុងព្រៃក្រាស់មួយជិតភូមិកំណើតរបស់ព្រះអង្គ។ ព្រៃនេះគ្មានមនុស្សនៅទេ ហើយល្បីថាជាទីកន្លែងនៃពស់វែក ខ្លា និងខ្មោចបិសាច។ ដោយហេតុនេះ ដូចជាព្រះអង្គបានមានថេរដីការួចហើយ វាជាទីកន្លែងមួយល្អឥតខ្ចោះសម្រាប់អរញ្ញភិក្ខុ។ នៅជុំវិញព្រះអាចារ្យ **ឆា** គេបានកសាងវត្តមួយធំ ដោយមកពីមានភិក្ខុ ដូនជី និងពុទ្ធបរិស័ទកាន់តែច្រើនឡើងៗ បាននិមន្តនិងអញ្ជើញមកស្តាប់ធម្មទេសនារបស់ព្រះអង្គ ហើយសម្នាក់នៅទីនោះ ដើម្បីប្រតិបត្តិកម្មដ្ឋានជាមួយព្រះអង្គ។ សព្វថ្ងៃនេះ មានសិស្សរបស់ព្រះអង្គជាច្រើនអង្គបង្រៀននៅទីវត្ត ចម្រើនកម្មដ្ឋានយ៉ាងច្រើន ទូទៅក្នុងសកលលោក។

ពេលចូលទៅក្នុងវត្ត **ណងប៉ាផុង** គេច្រើនតែប្រទះឃើញបព្វជិតយោងទឹកចេញពីអណ្តូង និងសញ្ញាមួយលើផ្លូវដើរ ដាក់ថា: «សូមស្ងាត់! យើងកំពុងសាកល្បងចម្រើនកម្មដ្ឋាន»។ ថ្វីបើមានការអង្គុយចម្រើនកម្មដ្ឋានរួមគ្នាពីរដងក្នុងមួយថ្ងៃ ហើយជួនកាលមានធម្មទេសនាមួយ សម្តែងដោយព្រះអាចារ្យ **ឆា** ផងក្តី, ខ្លឹមសារនៃការចម្រើនកម្មដ្ឋាន ជារបស់នៃការរស់នៅ។ បព្វជិតទាំងឡាយធ្វើការហត្ថកម្ម ជ្រលក់ និងដេរចីវរផ្ទាល់ខ្លួន, ធ្វើគ្រឿងបរិក្ខារប្រើប្រាស់ផ្ទាល់ខ្លួនភាគច្រើន ហើយថែទាំអាគារនិងទីវត្តឲ្យបានល្អឥតខ្ចោះ។ នៅទីនេះ បព្វជិតរស់នៅតឹងរ៉ឹងណាស់ ដោយប្រតិបត្តិតាមសមណសីល ឆាន់ក្នុងបាត្រ ម្តងក្នុងមួយថ្ងៃ ហើយមានកម្រិតគ្រឿងបរិក្ខារនិងចីវរ។ មានតូបដាច់ដោយឡែកពីគ្នាច្រើន នៅពាសពេញព្រៃ សម្រាប់ឲ្យបព្វជិតរស់នៅនិងចម្រើនកម្មដ្ឋានដាច់តែម្នាក់ឯង ហើយនិងដើរចង្ក្រមតាមផ្លូវក្រោយក្រោមដើមឈើ។

វិន័យតឹងរ៉ឹងយ៉ាងមហិមា អាចនាំឲ្យគេមានជីវិតរស់នៅធម្មតាហើយបរិសុទ្ធ នៅក្នុងសង្គមមួយស្រុះស្រួលគ្នា ដែលអាចឲ្យគេបណ្តុះបណ្តាលបានយ៉ាងប៉ិនប្រសប់និងជាប់រហូតនូវគុណធម៌ការចម្រើនកម្មដ្ឋាន និងការយោគយល់គ្នា។

គតិបណ្ឌិតជារបៀបរស់នៅនិងបិតនៅ ហើយព្រះអាចារ្យ **ឆា** បានខិតខំការពាររបៀបរស់នៅបរិសុទ្ធនៃបព្វជិត ដើម្បីឲ្យប្រជាជនអាចរៀននិងប្រតិបត្តិធម៌បាន នាពេលបច្ចុប្បន្ននេះ។

របៀបប្រៀនប្រដៅយ៉ាងងាយអស្ចារ្យរបស់ព្រះអាចារ្យ **ឆា** អាចនាំឲ្យមានការយល់ច្រឡំ។ ជាញឹកញយណាស់, លុះត្រាតែយើងបានស្តាប់អ្វីមួយច្រើនដង ទើបចិត្តរបស់យើងបានជ្រះថ្លាភ្លាមមួយរំពេច ហើយតាមរបៀបហ្នឹង ការប្រៀនប្រដៅក្លាយទៅជាមានន័យជ្រៅជាងមុនច្រើនណាស់។ ការប៉ិនប្រសប់របស់ព្រះអង្គក្នុងការច្នៃ ការពន្យល់ធម៌ ស្របតាមពេលវេលានិងទីកន្លែង ស្របតាមកម្រិតការយល់និងការឆាប់ចាប់អារម្មណ៍នៃសវនការ គួរឲ្យអស្ចារ្យនឹងឃើញណាស់។ ប៉ុន្តែជួនកាល នៅលើក្រដាស វាអាចធ្វើឲ្យគេយល់ឃើញថា ព្រះអង្គហាក់ដូចជាមិនប្រាកដ ឬមានថេរដីកាជាន់កែងខ្លួនឯងទៀតផង! ក្នុងករណីបែបហ្នឹង អ្នកអានត្រូវនឹកឃើញថា ពាក្យទាំងឡាយនេះ ជាកំណត់នៃការពិសោធរស់រវើក។ ដូចគ្នានេះដែរ, ជួនកាល បើការប្រៀនប្រដៅហាក់ដូចជាឃ្លាតពីប្រពៃណី គេត្រូវចាំទុកក្នុងចិត្តថា ព្រះអាចារ្យមានថេរដីកាចេញពីបេះដូងមកជានិច្ច, ចេញពីក្នុងទីជម្រៅនៃការពិសោធ តាមការភាវនាកម្មដ្ឋានផ្ទាល់របស់ព្រះអង្គ។

(ព្រះអង្គសុគតនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ ១៩៩២)

# **កំណាត់អ្នកប្រែ**

នៅដើមខែមិថុនា ១៩៩៩ លោក **ដេវីដ វីរតុន** បានសុំអនុញ្ញាតពីខ្ញុំ ដើម្បីយកអត្ថបទភាសាខ្មែរ «ផ្ទះពិតប្រាកដរបស់យើង» ដែលខ្ញុំបានប្រែពីភាសាអង់គ្លេសមក ទៅចាត់ចែងបោះពុម្ពផ្សាយជាធម្មទាន នៅប្រទេសកម្ពុជា។ ខ្ញុំក៏បានយល់ព្រមភ្លាម ដោយគំនិតដ៏ប្រពៃនេះ ស្របតាមគោលបំណងចម្បងរបស់ខ្ញុំ ក្នុងការផ្សព្វផ្សាយព្រះធម៌នៅមាតុប្រទេសជាទីស្នេហារបស់ខ្ញុំ។

អត្ថបទ (ជាភាសាអង់គ្លេសនិងភាសាខ្មែរ) ត្រូវបានបោះពុម្ពចែកជាធម្មទានដោយព្រះភិក្ខុ **ឯិន ភេន *ឥន្ទបញ្ញោ*** វត្តពោធិវង្ស ប្រទេសបារាំង រួចម្តងមកហើយ កាលពីខែតុលា ឆ្នាំ ១៩៩៣។

ការបោះពុម្ពផ្សាយជាលើកទីពីរនេះ មានការកែសម្រួលពាក្យពេចន៍ និងបន្ថែមការខ្វះខាតខ្លះតាមសេចក្តីស្នើពីសំណាក់លោកអ្នកអានទាំងឡាយ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អត្ថបទនេះនឹងជួយលោកអ្នកអានទាំងឡាយ ដែលមិនទាន់មានសទ្ធាជ្រះថ្លា ឲ្យមានសទ្ធាជ្រះថ្លា សម្រេចចិត្តប្រតិបត្តិធម៌តទៅ, ហើយលោកអ្នកទាំងឡាយ ដែលមានសទ្ធាជ្រះថ្លាហើយ ឲ្យរឹងរឹតតែមានសទ្ធាជ្រះថ្លា; ហើយប្រតិបត្តិធម៌ត្រឹមត្រូវប្រសើរឡើងថែមទៀត ដើម្បីឲ្យឆាប់បានសម្រេចគោលដៅទីបំផុតគឺ **ព្រះនិព្វាន**។

សូមឲ្យព្រះធម៌បរិសុទ្ធ បានរីកចម្រើនទូទៅក្នុងសកលលោក! ដោយអានុភាពនៃព្រះធម៌បរិសុទ្ធ សូមឲ្យសព្វសត្វទាំងពួងបានប្រកបដោយសុភមង្គលពិតប្រាកដ, សុខដុមរមនាពិតប្រាកដ, សន្តិភាពពិតប្រាកដ!

ក្រុងឡុងដុង ថ្ងៃទី ០៥ កក្កដា ១៩៩៩

តន់ មៀន

# កំណត់អ្នកវាយអត្ថបទ

សៀវភៅ «ផ្ទះពិតប្រាកដរបស់យើង» នេះជាសៀវភៅគម្រប់ពីរហើយ ដែលខ្ញុំទទួលភារៈវាយអត្ថបទឡើងវិញ។

ក្នុងការវាយអត្ថបទនេះឡើងវិញ ខ្ញុំបានកែតម្រូវអក្ខរាវិរុទ្ធដែលខុសឲ្យត្រឹមត្រូវឡើងវិញតាមវចនានុក្រមខ្មែរ (វចនានុក្រម សម្ដេចព្រះសង្ឃរាជ ជួន-ណាត)។ មួយវិញទៀត ខ្ញុំបានសម្រួលនូវឃ្លាបេះខ្លះ ដោយដាក់បន្ថែមនូវខណ្ឌសញ្ញាផ្សេងៗ ដើម្បីខណ្ឌឃ្លាក្នុងសង្កាត់នៃប្រយោគឲ្យងាយអានងាយយល់សេចក្ដី។ ខ្ញុំបានព្យាយាមយ៉ាងយកចិត្តទុកដាក់ ក្នុងការដាក់បន្ថែមនូវខណ្ឌសញ្ញាទាំងនោះ, ធ្វើយ៉ាងណាចៀសវាងមិនឲ្យសេចក្ដីល្អៀងពីអត្ថបទដើម។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងដោយអចេតនា ដែលមានក្នុងកិច្ចការវាយអត្ថបទព្រះធម៌ធម្មទេសនានេះឡើងវិញ។

ជាចុងបញ្ចប់នេះ ខ្ញុំសូមលើកឡើងនូវបុណ្យដែលកើតអំពីកិច្ចការជាកុសលនេះ ឧទ្ទិស ថ្វាយប្រគេន ជូន ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មាតាបិតា បងប្អូន និងញាតិមិត្តទាំងឡាយក្នុងសង្សារវដ្តនេះ, សូមបាននូវចំណែកបុណ្យកុសលតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន។ ដោយអំណាចនៃផលានិសង្សនេះ សូមសេចក្ដីសម្រេចចូរកើតមានដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនញាតិមិត្តគ្រប់ៗគ្នា។ សូមឲ្យព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនញាតិមិត្តទាំងអស់, បានរួចផុតចាកទុក្ខ ហើយជួបប្រកបតែនឹងសេចក្ដីសុខតរៀងទៅ។ ដោយអំណាចនៃកិច្ចការជាកុសលទាំងឡាយនេះ សូមបានជាឧបនិស្ស័យក្នុងព្រះពុទ្ធសាសនា; ជ្រះថ្លាក្នុងគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដើម្បីបានបណ្ដុះនូវបញ្ញា ហើយចាក់ធ្លុះក្នុងធម៌ ត្រាស់ដឹងនូវព្រះនិព្វានព្វដ៏អនាគតកាល គ្រប់ៗគ្នាគ្រប់ៗព្រះអង្គទៅហោង។

ថ្ងៃពុធ ១៣កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៩
**ហេង រង្សី**

# ផ្ទះពិតប្រាកដរបស់យើង

ព្រះអាចារ្យ ឆា

SMISIS

# ផ្ទះពិតប្រាកដរបស់យើង

ឥឡូវនេះ សូមញាតិញោមប្ដេជ្ញាចិត្តស្ដាប់ធម៌ដោយគោរព។ ក្នុងរយៈពេលដែលអាត្មាភាពសម្ដែងព្រះធម៌នេះ សូមញាតិញោមប្រុងប្រយ័ត្ន យកចិត្តទុកដាក់ស្ដាប់ពាក្យសម្ដីរបស់អាត្មាភាព បីដូចជាព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នៅចំពោះមុខញាតិញោម ហើយទ្រង់សម្ដែងធម៌ទេសនា។ សូមញាតិញោមធ្មេចភ្នែក រៀបចំឥរិយាបថឲ្យបានស្រួល ហើយប្រមូលចិត្តឲ្យបានមូលនៅលើអារម្មណ៍តែមួយ។ សូមញាតិញោមបណ្ដោយឲ្យរតនៈត្រៃនៃគតិបណ្ឌិត សេចក្ដីពិត និងភាពបរិសុទ្ធតាំងនៅក្នុងចិត្តរបស់ញាតិញោម ដើម្បីសម្ដែងនូវការគោរពបូជាចំពោះព្រះសម្មាសម្ពុទ្ធ។

ថ្ងៃនេះ អាត្មាភាពអត់មានយករបស់អ្វីមកជូនញាតិញោមទេ មានតែព្រះធម៌របស់ព្រះពុទ្ធតែប៉ុណ្ណោះ។ សូមញាតិញោមយកចិត្តទុកដាក់ស្ដាប់ឲ្យមែនទែន។ ញាតិញោមត្រូវតែយល់ថា សូម្បីព្រះពុទ្ធផ្ទាល់ព្រះអង្គឯង ដែលពោរពេញដោយសីលធម៌ ក៏ទ្រង់មិនអាចចៀសផុតពីសេចក្ដីស្លាប់ គឺការបែកធ្លាយនៃរូបកាយបានដែរ។ នៅពេលដែលទ្រង់មានព្រះជន្មាយុចាស់ជរា ព្រះអង្គទ្រង់បានលះបង់រូបកាយរបស់ព្រះអង្គចោល ហើយទ្រង់បានបោះបង់ចោលនូវបន្ទុកយ៉ាងធ្ងន់នៃរូបកាយនេះ។ ឥឡូវនេះ ញាតិញោមក៏ដូច្នេះដែរ ត្រូវចេះរីករាយពេញចិត្តនឹងការពឹងពាក់លើរូបកាយរបស់ខ្លួន អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ញាតិញោមត្រូវតែដឹងថា វាល្មមគ្រប់គ្រាន់ហើយ។

ញាតិញោមអាចយករូបកាយនេះ ទៅប្រៀបធៀបនឹងគ្រឿងប្រើប្រាស់ក្នុងផ្ទះសម្បែង ដែលញាតិញោមមានជាយូរណាស់មកហើយ, ដូចជាកែវ ចានតូចធំ និងអ្វីៗផ្សេងទៀត។ កាលដែលញាតិញោមទើបនឹងបានវាមក របស់ទាំងនោះល្អស្អាត ហើយភ្លឺរលោង, តែឥឡូវនេះ ក្រោយពីបានប្រើប្រាស់វាអស់រយៈពេលយ៉ាងយូរមក វាចាប់ផ្ដើមរេចរឹលហើយ។ របស់ខ្លះបានទាំងបែកបាក់ ខ្លះក៏បាត់បង់ទៅហើយ; របស់ដែលនៅសល់ទាំងប៉ុន្មាន ក៏ចេះតែខូចខាតបន្តិចម្ដងៗ, វាមិនអាចមានរូបរាងល្អស្អាតរហូតបានឡើយ។ ធម្មជាតិរបស់វា គឺយ៉ាងនេះឯង; រូបកាយញាតិញោមក៏ដូច្នេះដែរៈ វាចេះតែប្រែប្រួលជានិច្ចកាល តាំងតែពីថ្ងៃកើត ហូរហែតាមវ័យក្មេង វ័យកណ្ដាល រហូតមកដល់វ័យចាស់ជរា សព្វថ្ងៃនេះ។ ញាតិញោមត្រូវតែទទួលស្គាល់ស្ថានភាពនេះ។ ព្រះពុទ្ធទ្រង់បានត្រាស់ថាៈ "សង្ខារទាំងឡាយ ទោះបីជាផ្លូវចិត្តឬកាយក្ដី មិនមែនជារបស់ខ្លួនទេ។ ធម្មជាតិរបស់វា គឺត្រូវតែប្រែប្រួលផ្លាស់ប្ដូរ។ សូមញាតិញោមពិនិត្យពិចារណាសេចក្ដីពិតនេះ រហូតទាល់តែបានយល់យ៉ាងច្បាស់លាស់។

រូបកាយនេះឯង ដែលដេកនៅទីនេះ កាន់តែអន់ថយខ្សោយទៅៗ, ជាសច្ចៈធម៌ ជាសេចក្ដីពិត។ សេចក្ដីពិតនៃរូបកាយនេះជា **សច្ចៈធម៌** និងជាការប្រៀនប្រដៅឥតប្រែប្រួលរបស់ព្រះសម្មាសម្ពុទ្ធ។ ព្រះពុទ្ធទ្រង់បានប្រៀនប្រដៅយើងឲ្យសម្លឹងមើលរូបកាយ ឲ្យពិនិត្យពិចារណាមើលវា ហើយសម្របសម្រួលតាមធម្មជាតិរបស់វា។ យើងត្រូវតែមានលទ្ធភាពរស់នៅជាសុខសាន្តជាមួយរូបកាយ ទោះបីវាស្ថិតនៅក្នុងស្ថានភាពយ៉ាងណាក៏ដោយ។ ព្រះពុទ្ធទ្រង់បានបង្រៀនថា យើងត្រូវតែធ្វើយ៉ាង

ណាឲ្យបានដឹងជាក់ច្បាស់ថាមានតែរូបកាយទេ ដែលជាប់ក្នុងគុក ហើយមិនបណ្តោយឲ្យចិត្តជាប់នៅក្នុងគុកជាមួយរូបកាយនេះឡើយ។ ឥឡូវនេះ នៅពេលដែលរូបកាយញាតិញោមអន់ថយ ហើយដុនដាបដោយជរាភាព សូមកុំប្រឆាំងនឹងវា; ប៉ុន្តែសូមកុំបណ្តោយឲ្យចិត្តញាតិញោមដុនដាបទៅជាមួយវា, សូមតម្កល់ចិត្តទុកនៅដោយឡែក។ សូមផ្តល់ថាមពលដល់ចិត្ត ដោយកាដឹងច្បាស់នូវសេចក្តីពិតនៃដំណើរការរបស់ធម្មជាតិ។ ព្រះពុទ្ធទ្រង់បានប្រៀនប្រដៅថា នេះជាធម្មជាតិនៃរូបកាយ; វាមិនអាចប្រព្រឹត្តទៅខុសពីនេះបានឡើយ គឺថា ក្រោយពីបានកើតមក រូបកាយក៏ត្រូវតែចាស់ជរា មានជំងឺ រួចហើយត្រូវស្លាប់។ នេះគឺជា សេចក្តីពិតជាក់ស្តែង ដែលញាតិញោមបានជួបប្រទះនៅពេលនេះ។ សូមសម្លឹងមើលរូបកាយដោយគតិបណ្ឌិត ហើយទទួលយកសេចក្តីពិតនេះ។ ទោះបីផ្ទះញាតិញោមត្រូវទឹកជន់លិចឬក៏ត្រូវភ្លើងឆេះខ្ទេចខ្ទីក្តី, ទោះបីមានគ្រោះថ្នាក់បែបណាមួយដល់ផ្ទះក្តី, សូមឲ្យរឿងនេះ កើតឡើងចំពោះតែផ្ទះប៉ុណ្ណោះចុះ។ បើមានទឹកជន់លិច សូមកុំបណ្តោយឲ្យវាជន់លិចលើចិត្តញាតិញោម; បើមានភ្លើងឆេះ សូមកុំបណ្តោយឲ្យវាឆេះដល់ចិត្តញាតិញោម។ សូមឲ្យតែផ្ទះ ដែលជារបស់ខាងក្រៅរូបញាតិញោមនោះ លិចទឹកជំនន់ឬឆេះទៅចុះ។ សូមឲ្យចិត្តញាតិញោមឈប់ជាប់ជំពាក់នឹងវាទៅ។ ពេលវេលាមកដល់ហើយ។

ញាតិញោមមានជីវិតរស់នៅយូរណាស់មកហើយ។ ភ្នែកញាតិញោម បានឃើញរូបរាងនិងពណ៌សម្បុរយ៉ាងច្រើន, ត្រចៀកញាតិញោម បានឮសំឡេងជាច្រើន; ញាតិញោមមានការពិសោធច្រើនណាស់។ ទាំងអស់នេះ វាគ្រាន់តែជាការពិសោធតែប៉ុណ្ណោះ។ ញាតិញោមធ្លាប់បានទទួលទានអាហារឆ្ងាញ់ៗ ហើយរស់ជាតិយ៉ាងឆ្ងាញ់នេះ គឺគ្រាន់តែជារស់ជាតិឆ្ងាញ់តែប៉ុណ្ណោះ, គ្មានអ្វីលើសពីនេះឡើយ។ រស់ជាតិមិនឆ្ងាញ់ ក៏គ្រាន់តែជារស់ជាតិមិនឆ្ងាញ់តែប៉ុណ្ណោះ, អស់តែត្រឹមនេះ។ បើភ្នែកឃើញរូបរាងល្អ វាគ្រាន់តែជារូបរាងល្អប៉ុណ្ណោះ, រូបអាក្រក់ ក៏គ្រាន់តែជារូបអាក្រក់តែប៉ុណ្ណោះ។ ត្រចៀកឮសំឡេងផ្អែមពីរោះ គ្មានអ្វីក្រៅពីនោះទៀតឡើយ។ សំឡេងមិនពីរោះ ក៏គ្រាន់តែជាសំឡេងមិនពីរោះប៉ុណ្ណោះ។

ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះពុទ្ធដីកាថា ទោះមានក្តី ក្រក្តី ក្មេងក្តី ចាស់ក្តី មនុស្សក្តី សត្វក្តី, គ្មានសត្វណាមួយក្នុងលោកនេះ អាចរក្សាខ្លួនក្នុងសភាពដដែលបានយូរឡើយៈ អ្វីៗទាំងអស់ តែងតែជួបប្រទះនឹងការប្រែប្រួលផ្លាស់ប្តូរនិងការព្រាត់ប្រាស់បែកគ្នា។ នេះជាការពិតជាក់ស្តែងនៃជីវិត ដែលយើងមិនអាចរករបស់អ្វីមកកែប្រែបានឡើយ។ ប៉ុន្តែព្រះពុទ្ធទ្រង់បានត្រាស់ថា ការដែលយើងអាចធ្វើបាន គឺពិនិត្យមើលរូបកាយនិងចិត្តឲ្យឃើញថា វាមិនមែនជារបស់ខ្លួន, វាមិនមែនជា «ខ្លួនអញ» ឬ «របស់អញ» ទេ។ វាគ្រាន់តែជាការពិតជាក់ស្តែង ក្នុងមួយរយៈពេលតែប៉ុណ្ណោះ។ វាដូចជាផ្ទះនេះអញ្ចឹងដែរ, វាគ្រាន់តែមានឈ្មោះថាជាផ្ទះរបស់ញាតិញោមតែប៉ុណ្ណឹង; ញាតិញោមមិនអាចយកវាទៅជាមួយ ទៅទីណាមួយបានឡើយ។ រីឯទ្រព្យសម្បត្តិទាំងឡាយនិងគ្រួសារ របស់ញាតិញោមក៏ដូចគ្នាដែរ; វាគ្រាន់តែមានឈ្មោះថាជារបស់ញាតិញោមតែប៉ុណ្ណោះ, ការពិតវាមិនមែនជារបស់ញាតិញោមទេ គឺជារបស់ធម្មជាតិ។

សេចក្តីពិតនេះ មិនមែនចំពោះតែញាតិញោមតែម្នាក់ឯងទេៈ មនុស្សរាល់រូបដូចគ្នាទាំងអស់ សូម្បីព្រះសម្មាសម្ពុទ្ធនិងសាវកទាំងឡាយរបស់ព្រះអង្គក៏ដូច្នេះដែរ។ ប្លែកខុសពីយើងតែត្រង់ថា ព្រះពុទ្ធនិងសាវកទាំងឡាយរបស់ព្រះអង្គ ទ្រង់ទទួលស្គាល់អ្វីៗទាំងឡាយតាមធាតុពិតរបស់វា, ព្រះអង្គទ្រង់ពុំបានឃើញមានអ្វីប្លែកពីនេះឡើយ។

អាស្រ័យហេតុនេះ ព្រះពុទ្ធទ្រង់បានបង្រៀនយើងឲ្យពិនិត្យមើលរូបកាយនេះ តាំងតែពីបាតជើងឡើងលើរហូតដល់បង្ហើយ រួចចុះក្រោមមកវិញរហូតដល់បាតជើង។ សូមគ្រាន់តែសម្លឹងមើលរូបកាយ, តើញាតិញោមឃើញមានរបស់អ្វីខ្លះ? តើមានអ្វីមួយដែលពិតជាល្អស្អាតឬទេ? តើញាតិញោមអាចឃើញមានសារៈសំខាន់នៅត្រង់កន្លែងណាឬទេ? រូបកាយទាំងមូលនេះ វាចេះតែរេចរឹលអន់ថយមិនឈប់ឈរ, ហើយព្រះពុទ្ធទ្រង់បានបង្រៀនយើងឲ្យដឹងថា រូបកាយនេះមិនមែនជារបស់យើងទេ។ ធម្មជាតិរបស់រូបកាយ គឺវាយ៉ាងនេះឯង ព្រោះថា សង្ខារធម៌ទាំងឡាយ រមែងតែងតែផ្លាស់ប្តូរ។ តើញាតិញោមចង់ឲ្យវាទៅជាយ៉ាងដូចម្តេចទៀតបាន? តាមពិតវាគ្មានខុសទាស់អ្វីនឹងធម្មជាតិប្រែប្រួលបែបនេះនៃរូបកាយទេ។ មិនមែនរូបកាយទេ ដែលធ្វើឲ្យញាតិញោមមានទុក្ខ, គឺការយល់ខុសរបស់ញាតិញោមទេ ដែលធ្វើឲ្យញាតិញោមកើតទុក្ខ។ កាលណាញាតិញោមមើលរបស់ល្អឃើញថាអាក្រក់ នោះវាមុខជានឹងមានការច្របូកច្របល់ជាមិនខាន។

បីដូចជាទឹកទន្លេ, តាមធម្មតាវាហូរចុះតាមជាន់ថ្នាក់ វាមិនហូរច្រាស់ឡើងលើទេ; នេះគឺធម្មជាតិរបស់វា។ បើនរណាម្នាក់ទៅឈរនៅមាត់ទន្លេ ឃើញទឹកហូរចុះក្រោមតាមសម្រួល ហើយល្ងេល្ងើចង់ឲ្យវាហូរច្រាស់ឡើងលើវិញ អ្នកនោះច្បាស់ជាខកចិត្តហើយ។ ទោះគាត់ធ្វើអ្វីក៏ដោយ គំនិតខុសរបស់គាត់ មិនអាចអនុញ្ញាតឲ្យចិត្តរបស់គាត់បានសុខសាន្តឡើយ។ គាត់មុខជាកើតទុក្ខដោយយោបល់ខុសរបស់គាត់, ដោយគាត់យល់ខុសរបៀបនេះ។ បើគាត់មានទស្សនៈត្រឹមត្រូវ គាត់នឹងយល់ថា ទឹកត្រូវតែហូរចុះក្រោមតាមជាន់ថ្នាក់។ ល្គឹកណាតែគាត់មិនយល់ឃើញយ៉ាងនេះ ហើយទទួលស្គាល់ការពិតជាក់ស្តែងនេះទេនោះ គាត់នៅតែអន្ទះអន្ទែងកើតទុក្ខរហូត។

ទន្លេដែលហូរចុះក្រោមតាមជាន់ថ្នាក់ ដូចជារូបកាយញាតិញោម។ ក្រោយពីក្មេងខ្ចីមក, ឥឡូវនេះ រូបកាយញាតិញោមក្លាយទៅជាចាស់, ហើយពេលនេះ វាដើរឆ្ពោះទៅរកសេចក្តីស្លាប់។ សូមកុំប្រាថ្នាចង់ឲ្យវាប្រព្រឹត្តទៅខុសពីនេះឲ្យសោះ មិនមែនជារឿងដែលញាតិញោមអាចកែប្រែបានទេ។ ព្រះពុទ្ធទ្រង់បានបង្រៀនយើងឲ្យយល់ឃើញអ្វីៗទាំងអស់តាមភាពពិតរបស់វា រួចហើយលះបង់នូវការជាប់ជំពាក់ចិត្តលើវាចេញទៅ។

សូមញាតិញោមយកមនោសញ្ចេតនាលះបង់នេះទុកជាទីពឹងទីនឹករលឹក។ សូមចេះតែចម្រើនកម្មដ្ឋានតទៅរហូត ទោះបីញាតិញោមរហិតរហៃយ៉ាងណាក៏ដោយ។ សូមបណ្តោយឲ្យចិត្តញាតិញោម តាំងនៅជាប់ជាមួយដង្ហើម។ សូមដកដង្ហើមវែង ពីរ-បីដង រួចហើយតាំងចិត្តនៅជាប់នឹងដង្ហើម ដោយប្រើពាក្យមន្តថា «ពុទ្ធោ»។ សូមប្រតិបត្តិតាមរបៀបនេះរៀងរហូតទៅ។ ដរាបណាញាតិញោមកាន់តែអស់កម្លាំងខ្លាំង ដរាបនោះការប្រមូលចិត្តឲ្យមូលរបស់ញាតិញោមត្រូវតែបានប្រសើរ

ឡើងដែរ ដើម្បីឲ្យញាតិញោមអាចទប់ទល់នឹងការឈឺចុកចាប់ដែលកើតឡើង។ កាលណាញាតិញោមចាប់អស់កម្លាំង ពេលនោះសូមឈប់លែងគិតអ្វីទាំងអស់។ សូមទុកឲ្យចិត្តប្រមូលផ្តុំខ្លួនឯង រួចហើយបែរទៅរកសតិដឹងលើដង្ហើម។ សូមគ្រាន់តែបន្តសូត្រធម៌ក្នុងចិត្តថា «ពុទ្ធោ! ពុទ្ធោ!» រហូតទៅ។ សូមបំភ្លេចកិច្ចការខាងក្រៅឲ្យអស់។ សូមកុំប្រកាន់ខ្ជាប់នឹងគំនិតគិតដល់កូនចៅនិងក្រុមញាតិ កុំប្រកាន់ខ្ជាប់នឹងរបស់អ្វីឲ្យសោះ។ សូមលះបង់វាចោលទៅ។ សូមបណ្តោយឲ្យចិត្តរួមមូលលើអារម្មណ៍តែមួយ ហើយឲ្យវាតាំងនៅជាប់នឹងដង្ហើម។ សូមឲ្យចិត្តតាំងនៅជាមួយនឹងដង្ហើមតែម៉្យាង។ សូមផ្ចង់ចិត្តរហូតទាល់តែវាក្លាយទៅជាស្រទន់ទៅៗ រហូតទាល់តែវេទនារម្មណ៍ខ្សោយទៅៗ, ហើយឃើញមានពន្លឺ និងការភ្ញាក់រឭកយ៉ាងប្រពៃ កើតឡើងនៅក្នុងចិត្ត។ នៅពេលនោះ កាលណាការឈឺចុកចាប់កើតមានឡើង វានឹងរំសាយរលាយបាត់តាមលំដាប់ ដោយឯកឯង។

ជាអវសាន ញោមនឹងទុកដង្ហើមដូចជាញាតិសន្តានអញ្ជើញមកសួរញាតិញោម។ កាលណាគេត្រឡប់ទៅវិញ យើងជូនដំណើរគេចេញទៅ។ យើងតាមមើលគេ រហូតទាល់តែគេដើរចេញផុត ឬក៏ជិះរថយន្តបរចេញទៅផុតកន្ទុយភ្នែក ទើបយើងត្រឡប់ចូលមកក្នុងផ្ទះវិញ។ យើងពិនិត្យមើលដង្ហើមតាមរបៀបដូចគ្នានេះដែរ។ បើដង្ហើមគ្រោតគ្រាត យើងដឹងថាវាគ្រោតគ្រាត, បើវាស្រទន់ យើងដឹងថាវាស្រទន់។ នៅពេលដែលវាក្លាយទៅជាស្រទន់ទៅៗ យើងចេះតែតាមពិនិត្យមើលវាជានិច្ច ដោយដាស់សតិរបស់យើងឲ្យភ្ញាក់រឭកនៅពេលជាមួយគ្នានេះ។ នៅទីបំផុតដង្ហើមរលត់បាត់អស់ មានតែការភ្ញាក់រឭកទេដែលនៅសល់; នេះហៅថាបានឃើញព្រះពុទ្ធ។ យើងមានការភ្ញាក់រឭកយ៉ាងភ្លឺស្វាង ដែលហៅថា «ពុទ្ធោ» គឺបុគ្គលដែលបានត្រាស់ដឹង បុគ្គលដែលភ្ញាក់រឭក បុគ្គលដែលភ្លឺស្វាង។ គឺជាការជួបនិងតាំងនៅជាមួយព្រះពុទ្ធ ប្រកបដោយវិជ្ជានិងពន្លឺភ្លឺស្វាង ព្រោះថា មានតែរូបកាយនៃព្រះពុទ្ធក្នុងប្រវត្តិសាស្ត្រទេ ដែលបានចូលនិព្វាន។ ព្រះពុទ្ធពិតប្រាកដ ព្រះពុទ្ធដែលជាការត្រាស់ដឹង ភ្លឺថ្លា ត្រចះត្រចង់នោះ, យើងអាចពិសោធឃើញ និងបានសម្រេចក្នុងពេលឥឡូវនេះ ហើយនៅពេលនោះ ចិត្តនឹងមូលមកតែមួយ។

ហេតុដូច្នេះ សូមញាតិញោមលះបង់ រលាស់ចោលអ្វីៗទាំងអស់ លើកលែងតែសតិដឹង។ បើមាននិមិត្តឬក៏សំឡេងផ្សេងៗកើតឡើងក្នុងចិត្ត នៅពេលចម្រើនកម្មដ្ឋាន សូមកុំរវល់នឹងវា។ សូមលះបង់វាចោលទាំងអស់។ សូមកុំជាប់ចិត្តលើអ្វីឲ្យសោះ។ សូមគ្រាន់តែតាំងនៅជាមួយសតិដឹងតែម៉្យាងនេះ។ សូមកុំខ្វល់នឹងអតីតកាលឬក៏អនាគតកាលឡើយ សូមស្ថិតនៅស្ងៀមស្ងប់។ ញាតិញោមនឹងបានទៅដល់ទីកន្លែងមួយ ដែលគ្មានការដើរទៅមុខ ដើរថយក្រោយ ឬនៅនឹងមួយកន្លែងទេ, គឺជាទីកន្លែង ដែលគ្មានវត្ថុអ្វីគួរជាទីជាប់ជំពាក់ចិត្ត ឬប្រកាន់ខ្ជាប់ឡើយ។ ហេតុអ្វី? ពីព្រោះវាគ្មាន «អញ» គ្មាន «ខ្លួនអញ» ឬ «របស់អញ» ទេ។ វារលាយបាត់អស់ទៅហើយ។ ព្រះពុទ្ធទ្រង់បានប្រៀនប្រដៅយើងឲ្យលះបង់អ្វីៗចោលទាំងអស់តាមរបៀបនេះ មិនឲ្យយកអ្វីទៅជាមួយសោះឡើយ។ សូមពិនិត្យមើលអ្វីៗទាំងអស់ ឲ្យបានស្គាល់ ឲ្យដឹងច្បាស់; លុះបានដឹងច្បាស់ហើយ លះបង់វាចោលទៅ។

ការបានសម្រេចព្រះធម៌ សម្រេចមាគ៌ានៃការរួចរំដោះពីវដ្តសង្សារ គឺជាកិច្ចការដែលយើង

គ្រប់គ្នាត្រូវតែធ្វើដោយខ្លួនឯង។ ដូច្នេះ សូមញាតិញោមសាកល្បងលះបង់ ហើយយល់ព្រះធម៌ឲ្យបានច្បាស់លាស់។ សូមញាតិញោមខិតខំឲ្យមែនទែន ក្នុងការចម្រើនកម្មដ្ឋាន។ សូមកុំព្រួយអំពីរឿងគ្រួសារញាតិញោម។ នៅពេលនេះ គ្រួសារញាតិញោមនៅតែដដែល; ទៅអនាគត គេនឹងប្រែក្លាយទៅដូចជាញាតិញោមដែរ។ ក្នុងលោកនេះ គ្មានជនណាម្នាក់ អាចចៀសវាងវាសនានេះបានឡើយ។ ព្រះពុទ្ធទ្រង់បានប្រៀនប្រដៅឲ្យទម្លាក់ចោលអ្វីៗទាំងអស់ ដែលគ្មានខ្លឹមសារពិតប្រាកដ។ បើញាតិញោមទម្លាក់អ្វីៗទាំងអស់ចោលទៅ ញាតិញោមនឹងឃើញសច្ចធម៌ ឃើញសេចក្ដីពិត។ បើញាតិញោមមិនធ្វើដូច្នេះទេ នោះញាតិញោមនឹងមិនបានឃើញសច្ចៈធម៌ ឃើញសេចក្ដីពិតឡើយ។ នេះគឺជាធម្មជាតិ, ហើយនៅក្នុងលោកនេះ ធម្មជាតិនេះ ដូចៗគ្នាទាំងអស់ សម្រាប់មនុស្សរាល់រូប។ ដូច្នេះ សូមញាតិញោមកុំព្រួយ ហើយកុំប្រកាន់ខ្ជាប់លើអ្វីឲ្យសោះ។

ទោះបីញាតិញោមដឹងខ្លួនឯងថា ញាតិញោមនៅចេះតែគិតក៏មិនទាស់ខុសអ្វីដែរ ដរាបណាញាតិញោមគិតដោយគតិបណ្ឌិត; សូមកុំគិតផ្ដេសផ្ដាស។ បើញាតិញោមគិតដល់កូនចៅ, សូមនឹកគិតដល់វាដោយគតិបណ្ឌិត មិនមែននឹកដោយល្ងេល្ងើលីលាទេ។ ទោះបីចិត្តងាកទៅលើអ្វីក៏ដោយ សូមនឹកគិតហើយទទួលស្គាល់របស់ទាំងនោះ ដោយគតិបណ្ឌិត ដោយយល់អំពីធម្មជាតិរបស់វា។ បើញាតិញោមស្គាល់របស់អ្វីៗ ដោយគតិបណ្ឌិត នោះញាតិញោមនឹងលះបង់វាចោលបាន ហើយឥតមានទុក្ខទេ។ ចិត្តក៏បានភ្លឺថ្លារីករាយនិងសុខសាន្ត ផុតចាកពីការរំខានផ្សេងៗ; ជាចិត្តមូលតែមួយ។ នៅពេលឥឡូវនេះ របស់ដែលញាតិញោមអាចយកមកពឹងពាក់ជាជំនួយបាន គឺដង្ហើមរបស់ញាតិញោម។

នេះជាកិច្ចការផ្ទាល់ខ្លួនរបស់ញាតិញោម មិនមែនជាកិច្ចការរបស់អ្នកណាឯទៀតទេ។ សូមទុកឲ្យអ្នកឯទៀតបំពេញកិច្ចការរបស់គេចុះ។ ញាតិញោមមានភារកិច្ចនិងការទទួលខុសត្រូវផ្ទាល់ខ្លួន ហើយញាតិញោមមិនត្រូវទទួលយកភារកិច្ចនៃគ្រួសារញាតិញោមទេ។ សូមកុំទទួលយករបស់អ្វីមកទៀត សូមលះបង់វាចោលឲ្យអស់ទៅ។ ការលះបង់នេះ នឹងធ្វើឲ្យចិត្តញាតិញោមបានស្ងប់។ នៅពេលនេះ ភារកិច្ចតែមួយរបស់ញាតិញោម គឺប្រមូល ហើយទាញចិត្តរបស់ញាតិញោមមករកសន្តិភាព។ អ្វីៗក្រៅពីនេះ សូមទុកវាឲ្យអ្នកឯទៀតចុះ។ រូប សំឡេង ក្លិន រសជាតិទាំងឡាយ, សូមទុកឲ្យអ្នកឯទៀតគិតគូរចុះ។ សូមទម្លាក់អ្វីៗចោលទាំងអស់ ហើយធ្វើការបំពេញភារកិច្ចតែមួយរបស់ញាតិញោម។ អ្វីៗទាំងអស់ ដែលកើតឡើងក្នុងចិត្តញាតិញោម ដូចជាខ្លាចឈឺចុកចាប់ ខ្លាចស្លាប់ ព្រួយអំពីអ្នកដទៃ ឬអ្វីៗទៀតក៏ដោយ, សូមប្រាប់វាថាៈ «កុំមករំខានអញ អញឈប់ លែងរវល់នឹងអ្នកឯងទៀតហើយ»។ សូមចេះតែនិយាយថាដូច្នេះទៅខ្លួនឯង នៅពេលណាដែលធម៌ទាំងឡាយនេះកើតឡើងក្នុងចិត្តញាតិញោម។

តើពាក្យថា «ធម៌» សំដៅទៅលើអ្វី? អ្វីៗទាំងអស់ក្នុងលោកនេះ ហៅថា **ធម៌**។ គ្មានរបស់អ្វីមួយដែលមិនមែនជាធម៌ទេ។ ចុះពាក្យថា «លោក» នេះជាអ្វីដែរ? **លោក** គឺជា ស្ថានភាពនៃចិត្តដែលធ្វើឲ្យញាតិញោមខ្វល់ខ្វាយនៅពេលនេះ។ គិតថាៈ «តើអ្នកនេះនឹងធ្វើអ្វីហ្នឹ? តើអ្នកនោះនឹងធ្វើអ្វីហ្នឹ?

នៅពេលអញស្លាប់ទៅ តើអ្នកណានឹងមើលថែរក្សាវា? តើវានឹងរស់នៅរបៀបណា?» ទាំងអស់នេះជា «លោក»។ សូម្បីការនឹកឃើញខ្លាចស្លាប់ ឬខ្លាចឈឺចាប់ក៏ហៅថាលោកដែរ។

ញាតិញោមបោះបង់លោកចោលទៅ! លោកគឺជា ដំណើរប្រព្រឹត្តទៅតាមធម្មតា។ បើញាតិញោមបណ្ដោយឲ្យវាកើតឡើងក្នុងចិត្ត ហើយគ្របសង្កត់លើចិត្តបាននោះ, ចិត្តនឹងក្លាយទៅជាងងឹតងងល់ ហើយមិនអាចមើលខ្លួនឯងឃើញបានទេ។ ហេតុដូច្នេះ ទោះអ្វីកើតឡើងក្នុងចិត្តក៏ដោយ សូមគ្រាន់តែគិតថា: «វាមិនមែនជាកិច្ចការរបស់អញទេ»។

ការគិតថា ញាតិញោមចង់រស់ឲ្យបានយូរ នឹងធ្វើឲ្យញាតិញោមកើតទុក្ខ។ ប៉ុន្តែការគិតថាញាតិញោមចង់ស្លាប់ភ្លាមៗ ឬស្លាប់ក្នុងពេលឆាប់ៗនេះ, ក៏មិនល្អដែរ គឺជាទុក្ខមែនឬទេ? បាតុភូតទាំងឡាយ មិនមែនជារបស់យើងទេ, វាប្រព្រឹត្តទៅតាមច្បាប់ធម្មជាតិផ្ទាល់របស់វា។ ញាតិញោមមិនអាចធ្វើអីកើតទេ ចំពោះដំណើរការណ៍នៃរូបនេះ។ ញាតិញោមអាចធ្វើឲ្យវាស្អាតបន្តិច ធ្វើឲ្យវាមានសម្រស់ល្អបន្តិច និងស្អាតបាតបានមួយរយៈពេល; ដូចជាយុវនារីទាំងឡាយ ដែលលាបបបូរមាត់ ហើយទុកក្រចកឲ្យវែង, ប៉ុន្តែដល់ជរាមកដល់ មនុស្សរាល់រូបក្នុងនាវាតែមួយ គឺចាស់ជរាដូចគ្នាទាំងអស់។ នេះគឺជា ធម្មជាតិរបស់រូបកាយ; ញាតិញោមមិនអាចកែប្រែវាបានឡើយ។ ប៉ុន្តែរបស់ដែលញាតិញោមអាចធ្វើឲ្យល្អប្រពៃបានគឺ **ចិត្ត**។ នរណាក៏អាចសង់ផ្ទះអំពីឈើឬថ្មបានដែរ ប៉ុន្តែព្រះពុទ្ធទ្រង់បានប្រៀនប្រដៅថា ផ្ទះបែបហ្នឹងមិនមែនជាផ្ទះពិតប្រាកដរបស់យើងទេ, វាគ្រាន់តែជារបស់យើងតាមធម្មតាប៉ុណ្ណោះ។ វាជាផ្ទះមួយក្នុងលោក ហើយវាដើរតាមផ្លូវនៃលោក។

ផ្ទះពិតប្រាកដរបស់យើងគឺ **សន្តិភាពខាងក្នុង**។ ផ្ទះដែលជារបស់ខាងក្រៅ អាចល្អស្អាតពិតមែនហើយ តែវាមិនសូវមានសន្តិភាពទេ។ វាចេះតែមានកង្វល់យ៉ាងនេះ រួចហើយយ៉ាងនោះ, សេចក្ដីព្រួយបារម្ភយ៉ាងនេះ រួចហើយយ៉ាងនោះទៀត។ ដូច្នេះ យើងនិយាយថា វាមិនមែនជាផ្ទះពិតប្រាកដរបស់យើងទេ, វាជារបស់ក្រៅខ្លួនយើង; ទោះយូរឬឆាប់ យើងនឹងត្រូវតែលះបង់វាចោល។ មិនមែនជាទីកន្លែងដែលយើងអាចរស់នៅរហូតបានទេ ពីព្រោះវាមិនមែនជារបស់យើងពិតប្រាកដ; វាជាផ្នែកមួយនៃលោក។

រូបកាយយើងក៏ដូចគ្នាដែរ: យើងទុកវាថាជាខ្លួន ជា «អញ» ជា «របស់អញ» ប៉ុន្តែតាមពិត វាមិនមែនដូច្នេះសោះទេ, រូបកាយជាផ្ទះម្យ៉ាងផ្សេងទៀតនៃលោក។ រូបកាយញាតិញោម ធ្វើដំណើរតាមធម្មជាតិរបស់វា; តាំងតែពីកំណើតមកដល់ពេលនេះ វាចាស់ហើយឈឺ, ញាតិញោមមិនអាចហាមឃាត់វាមិនឲ្យទៅជាយ៉ាងនេះបានទេ; នេះជាធម្មជាតិរបស់វា។ ការចង់ឲ្យវាប្លែកខុសពីនេះ គឺភ្លីភ្លើលីលា ប្រហែលគ្នានឹងការចង់ឲ្យសត្វទាក្លាយទៅជាសត្វមាន់ដែរ។ កាលណាញាតិញោមឃើញថា សភាពការណ៍បែបនេះមិនអាចធ្វើទៅកើតទេ; ទាត្រូវតែនៅជាទា, មាន់ត្រូវតែនៅជាមាន់, រូបកាយត្រូវតែចាស់ជរា រួចហើយស្លាប់; ញាតិញោមនឹងមានកម្លាំងនិងថាមពលឡើង។ ទោះបីញាតិញោមចង់ឲ្យរូបកាយស្ថិតនៅបានយូរយ៉ាងណាក្ដី ក៏វានឹងមិនអាចនៅបានដែរ។

ព្រះពុទ្ធទ្រង់ត្រាស់ថា:

«អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ

ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ»

ប្រែថា: «សង្ខារទាំងឡាយ មិនទៀងមែនពិត មានកិរិយាកើតឡើងនិងវិនាសបាត់ទៅវិញជាធម្មតា កើតឡើងហើយ តែងតែរលត់ទៅវិញ ការរលត់បាត់ទៅនៃសង្ខារទាំងឡាយ នាំមកនូវសេចក្ដីសុខពិតប្រាកដ។»

ពាក្យថា «សង្ខារ» សំដៅទៅលើរូបកាយនឹងចិត្តនេះឯង។ សង្ខារទាំងឡាយមិនទៀងហើយប្រែប្រួល, កើតឡើងហើយវិនាសទៅវិញ; តែមនុស្សរាល់រូបចង់នៅវាស្ថិតនៅរហូត, នេះជាភាពល្ងីល្ងើលីលា។ សូមសង្កេតមើលដង្ហើមមើល៍។ ដង្ហើមចូលមកហើយចេញទៅវិញ; នេះជាធម្មជាតិរបស់វា, វាត្រូវតែប្រព្រឹត្តទៅយ៉ាងនេះ។ ដង្ហើមចូលនិងដង្ហើមចេញ ត្រូវផ្លាស់ប្ដូរគ្នា, វាត្រូវតែមានការផ្លាស់ប្ដូរ។ សង្ខារទាំងឡាយ កើតឡើងតាមការផ្លាស់ប្ដូរ; ញាតិញោមមិនអាចហាមឃាត់វាបានទេ។ សូមគ្រាន់តែគិតមើលថា: «តើញាតិញោមអាចដកដង្ហើមចេញ ដោយមិនបាច់ដកដង្ហើមចូលបានឬទេ? តើធ្វើដូច្នេះបានស្រួលខ្លួនឬទេ? ឬក៏ញាតិញោមអាចគ្រាន់តែដកដង្ហើមចូលតែម៉្យាងបានដែរឬទេ?» យើងចង់ឲ្យវត្ថុទាំងឡាយស្ថិតនៅរហូត តែវាមិនអាចស្ថិតនៅរហូតបានទេ; វាមិនអាចធ្វើយ៉ាងនេះបានឡើយ។ កាលណាដង្ហើមបានចូលមករួចហើយ វាត្រូវតែចេញទៅវិញ, កាលណាវាបានចេញផុតទៅហើយ វាត្រូវតែចូលមកជាថ្មីម្ដងទៀត។ នេះជាធម្មជាតិមែនឬទេ? ក្រោយពីបានកើតឡើង យើងប្រែទៅជាចាស់ ហើយឈឺ រួចហើយស្លាប់, នេះជាការធម្មតាទេ។ ដោយសារតែសង្ខារទាំងឡាយ បានបំពេញមុខងាររបស់វា, ដោយសារតែដង្ហើមចូលនិងដង្ហើមចេញ ផ្លាស់ប្ដូរគ្នាយ៉ាងនេះហើយ ទើបបានជាមនុស្សជាតិនៅមាននៅទីនេះដល់សព្វថ្ងៃ។

នៅពេលដែលយើងកើតភ្លាម យើងត្រូវស្លាប់ទៅវិញ។ ការកើតនិងស្លាប់របស់យើងជារបស់តែមួយ; វាដូចជាឈើមួយដើម; កាលណាមានឫស ត្រូវតែមានមែក, កាលណាមានមែក ត្រូវតែមានឫស។ យើងមិនអាចមានរបស់មួយ ដោយមិនអាចមានមួយទៀតនោះទេ។ គួរឲ្យចង់សើចបន្តិចដែរ ដោយឃើញមនុស្សនានាកើតទុក្ខ ខ្វល់ខ្វាយ យំស្រែកយ៉ាងខ្លាំង នៅពេលណាមានមរណភាព, ហើយអបអរជាពន្លឹក នៅពេលមានកំណើត។ នេះជាការយល់ច្រឡំ គ្មានជនណាម្នាក់ដែលបានសង្កេតមើលរឿងនេះ ឲ្យបានច្បាស់លាស់ទេ។ អាត្មាភាពយល់ឃើញថា បើលោកអ្នកចង់យំមែនទែន ជាការប្រសើរគួរតែយំនៅពេលដែលមាននរណាម្នាក់កើត ដោយមកពីហេតុថា តាមការពិតកំណើតគឺមរណភាព, មរណភាពគឺកំណើត, ឫសគឺមែក, មែកគឺឫស។ បើត្រូវយំ យំត្រង់ឫស, យំនៅពេលកើត។ សូមសង្កេតមើលឲ្យច្បាស់មែនទែន: បើគ្មានកំណើតទេ មរណភាពក៏គ្មានដែរ។ តើញាតិញោមយល់រឿងនេះបានឬទេ?

សូមញាតិញោមកុំគិតច្រើនពេក។ សូមគ្រាន់តែគិតថា: «នេះគឺជាច្បាប់ធម្មជាតិ»។ វាជាកិច្ចការ ជាភារកិច្ចរបស់ញាតិញោម។ នៅពេលនេះ គ្មាននរណាម្នាក់អាចជួយញាតិញោមបានទេ; គ្មានអ្វីដែលគ្រួសារ ឬទ្រព្យសម្បត្តិទាំងអស់របស់ញាតិញោម អាចជួយញាតិញោមបានទេ។ មានតែសតិ

ដឹងត្រឹមត្រូវទេ ដែលអាចជួយញាតិញោមបាន។ ដូច្នេះ សូមញាតិញោមកុំរន្ធត់, សូមលះបង់, សូមបោះវាចោលឲ្យអស់ទៅ។

ទោះបីបើញាតិញោមមិនលះបង់វាក៏ដោយ, អ្វីៗទាំងអស់ ចាប់ផ្តើមចាកចេញពីញាតិញោមហើយ។ តើញាតិញោមឃើញឬទេ ផ្នែកផ្សេងៗនៃរូបកាយញាតិញោម កំពុងតែខិតខំរបេះចេញពីគ្នាយ៉ាងនេះ? សូមពិនិត្យមើលសក់: កាលណាញាតិញោមនៅក្មេង សក់ខ្មៅហើយក្រាស់, ឥឡូវនេះវាជ្រុះ វាចាកចេញហើយ។ ភ្នែកញាតិញោមធ្លាប់មានសុខភាពល្អ មើលឃើញច្បាស់, ហើយឥឡូវនេះវាខ្សោយ ញាតិញោមមើលឃើញមិនច្បាស់ទេ។ កាលណាអវយវៈទាំងឡាយដល់កំណត់វាហើយ វាចាកចេញទៅ, ទីនេះមិនមែនជាផ្ទះរបស់វាទេ។ កាលញាតិញោមនៅក្មេង ធ្មេញញាតិញោមមានសុខភាពរឹងមាំ, ឥឡូវនេះវារង្គោះរង្គើ ប្រហែលជាញាតិញោមពាក់ធ្មេញធ្វើដោយដៃផងទេដឹង! ត្រចៀក ច្រមុះ អណ្តាតរបស់ញាតិញោម អ្វីៗទាំងអស់ចេះតែខិតខំចាកចេញទៅហើយ ពីព្រោះទីកន្លែងនេះមិនមែនជាផ្ទះរបស់វា។ ញាតិញោមមិនអាចយកសង្ខារមកធ្វើជាផ្ទះបានស្ថិតស្ថេរហ្មតឡើយ។ ញាតិញោមអាចសំណាក់នៅបានមួយរយៈកាលខ្លី រួចហើយត្រូវតែចាកចេញទៅ។ បីដូចជាអ្នកជួលផ្ទះគេនៅ សម្លឹងមើលផ្ទះតូចមួយជាមួយនឹងភ្នែកជនពិការអញ្ចឹងដែរ។ ធ្មេញរបស់គាត់មិនសូវល្អ, ត្រចៀកក៏មិនសូវវៃ, រូបកាយក៏មិនសូវមានសុខភាពល្អដែរ; អ្វីទាំងអស់កំពុងតែចាកចេញទៅហើយ។

ហេតុដូច្នេះ ញាតិញោមមិនចាំបាច់ព្រួយបារម្ភអំពីអ្វីៗទាំងអស់ ពីព្រោះវាមិនមែនជាផ្ទះពិតប្រាកដរបស់ញាតិញោមទេ។ វាគ្រាន់តែជាជម្រកបណ្តោះអាសន្នតែប៉ុណ្ណោះ។ ដោយបានមកកើតក្នុងលោកនេះ ញាតិញោមត្រូវតែពិនិត្យមើលធម្មជាតិរបស់វា។ របស់ដែលមានទាំងប៉ុន្មាន វាបម្រុងតែនឹងរលាយបាត់ទៅវិញ។ សូមសម្លឹងមើលរូបកាយរបស់ញាតិញោមមើល៍។ តើញាតិញោមមានឃើញមានរបស់អ្វីមួយដែលស្ថិតនៅដដែលដូចដើមឬទេ? តើស្បែករបស់ញាតិញោមនៅដដែលដូចដើមឬទេ? ចុះសក់យ៉ាងណាដែរ? វាឥតនៅដូចដើមទេ មែនឬទេ? តើរបស់អស់ទាំងនេះនៅឯណា? នេះគឺជាធម្មជាតិ, ជាច្បាប់ធម្មជាតិ។ កាលណាដល់កំណត់ បាតុភូតទាំងឡាយ ប្រព្រឹត្តទៅតាមផ្លូវរបស់វា។ លោកនេះមិនមែនជារបស់ពឹងពាក់បានឡើយ គឺជាវង់មូលគ្មានទីបំផុត នៃការជ្រួលច្របល់និងវិបត្តិ នៃការសប្បាយនិងទុក្ខ។ គ្មានសន្តិភាពទេ។

កាលណាយើងគ្មានផ្ទះពិតប្រាកដទេ យើងដូចជាអ្នកដំណើរម្នាក់ដើរតាមថ្នល់ឥតមានទីដៅ, ដើរទៅទិសនេះបន្តិច រួចហើយដើរទៅទិសនោះឈប់មួយសន្ទុះ រួចហើយដើរតទៅទៀត។ ល្គឹកណាយើងមិនទាន់ត្រឡប់ទៅផ្ទះពិតប្រាកដរបស់យើងទេនោះ, ទោះយើងធ្វើអ្វីក៏ដោយ យើងចេះតែរសាប់រសល់ ដូចគ្នាបេះបិទនឹងមនុស្សម្នាក់ដែលបានធ្វើដំណើរចេញពីភូមិរបស់ខ្លួនអញ្ចឹងដែរ។ លុះត្រាតែកាលណាគាត់ត្រឡប់មកផ្ទះវិញ ទើបគាត់អាចសម្រាកបានដោយសុខសាន្ត។

ក្នុងលោកនេះ គេមិនអាចរកឃើញសន្តិភាពនៅទីកន្លែងណាមួយឡើយ។ អ្នកក្រីក្រគ្មានសន្តិភាពទេ រីឯអ្នកមានក៏គ្មានសន្តិភាពដែរ។ មនុស្សពេញវ័យទាំងឡាយក៏គ្មានសន្តិភាព, កូនក្មេង

ទាំងឡាយក៏គ្មានសន្តិភាព, អ្នកមានចំណេះតិចតួចក៏គ្មានសន្តិភាព, រីឯអ្នកមានចំណេះខ្ពង់ខ្ពស់ក៏គ្មានសន្តិភាពដែរ។ នៅទីកន្លែងណាក៏គ្មានសន្តិភាពដែរ។ នេះហើយជាធម្មជាតិនៃលោក។

អ្នកមានទ្រព្យសម្បត្តិតិចតួចមានទុក្ខ រីឯអ្នកមានទ្រព្យសម្បត្តិច្រើនក៏មានទុក្ខដែរ។ កូនក្មេង មនុស្សពេញវ័យ មនុស្សចាស់ទាំងឡាយ... គ្រប់រូបទាំងអស់, សុទ្ធតែមានទុក្ខ។ រងទុក្ខដោយជរាភាព , រងទុក្ខដោយនៅក្មេង, រងទុក្ខដោយមានសម្បត្តិស្តុកស្តម្ភ, ហើយរងទុក្ខដោយក្រីក្រ, សុទ្ធតែទុក្ខទាំងអស់ គ្មានអ្វីក្រៅពីទុក្ខឡើយ។

កាលណាញាតិញោមបានពិនិត្យពិចារណាមើលអ្វីៗតាមរបៀបនេះ ញាតិញោមនឹងឃើញ អនិច្ចំ សេចក្តីមិនទៀង និង ទុក្ខំ សេចក្តីមិនពេញចិត្ត។ ហេតុអ្វីបានជាអ្វីៗទាំងឡាយមិនទៀង ហើយមិនជាទីពេញចិត្ត? ពីព្រោះមកពីវា អនត្តា មិនមែនរបស់ខ្លួន។

រូបកាយដែលដេកឈឺចុកចាប់នៅទីនេះ ចិត្តដែលដឹងថាមានជំងឺឈឺចុកចាប់, ទាំងពីរនេះហៅថា **ធម៌**។ របស់ដែលគ្មានរូបរាង ដូចជាគំនិតវេទនានិងសញ្ញាទាំងឡាយ ហៅថា **នាមធម៌**។ របស់ដែលត្រូវរួបរឹតដោយដោយការឈឺចុកចាប់ផ្សេងៗនេះ ហៅថា ***រូបធម៌***។ របស់ដែលមានរូបរាង ហៅថា ធម៌, រីឯរបស់គ្មានរូបរាង ក៏ហៅថា ធម៌ ដែរ។ តាមការពិត គេគ្មានឃើញ «ខ្លួនអញ» នៅទីកន្លែងណាឡើយ, មានតែធម៌ទាំងឡាយ ដែលចេះតែកើត-រលត់ កើត-រលត់ មិនឈប់ឈរ ស្របតាមធម្មជាតិរបស់វា។ យើងកើត-ស្លាប់ កើត-ស្លាប់ គ្រប់រយៈពេល វេលា។ នេះជាច្បាប់ធម្មជាតិ។

កាលណាយើងគិតដល់ព្រះពុទ្ធ គិតដល់ព្រះពុទ្ធវចនៈយ៉ាងត្រឹមត្រូវពិតប្រាកដ, យើងយល់ថាព្រះអង្គគួរជាទីគោរពបូជាក្រៃលែង។ នៅពេលណាដែលយើងឃើញការពិតនៃរបស់អ្វីមួយ យើងឃើញការប្រៀនប្រដៅរបស់ព្រះអង្គ ឃើញព្រះធម៌ ទោះបីយើងមិនដែលបានប្រតិបត្តិព្រះធម៌សោះក៏ដោយ។ ប៉ុន្តែបើយើងបានស្តាប់ បានរៀន បានប្រតិបត្តិព្រះធម៌ តែមិនទាន់បានឃើញការពិតនៅឡើយទេនោះ គឺយើងនៅមិនទាន់មានផ្ទះសម្បែងនៅឡើយទេ។

សូមយល់អំពីចំណុចនេះថា មនុស្សគ្រប់រូប សព្វសត្វទាំងឡាយ បម្រុងតែនឹងចាកចេញទៅ។ កាលណាសត្វទាំងឡាយបានរស់នៅអស់រយៈកាលត្រឹមត្រូវហើយ វាទៅតាមដំណើររបស់វា។ អ្នកមាន អ្នកក្រ ក្មេងឬចាស់ សត្វលោកទាំងអស់ ត្រូវតែបានពិសោធការប្រែប្រួលនេះ។

កាលណាញាតិញោមដឹងថា លោកតែងតែប្រែប្រួលតាមរបៀបនេះឯង, ញាតិញោមដឹងថាលោកជាទីមិនគួរគាប់ចិត្តឡើយ។ កាលណាញាតិញោមឃើញថា គ្មានរបស់អ្វីឋិតថេរឬមានខ្លឹមសារដែលញាតិញោមពឹងពាក់បានឡើយនោះ, ញាតិញោមកើតមានការរសាយនិងនឿយណាយក្នុងចិត្ត។

តែការនឿយណាយក្នុងចិត្តនេះ មិនមែនមានន័យថាស្អប់ខ្ពើមទេ។ ចិត្តភ្លឺស្វាង, វាមើលឃើញថា គ្មានមធ្យោបាយអ្វីអាចកែប្រែស្ថានភាពនេះបានឡើយ; លោកគឺវាយ៉ាងដូច្នេះឯង។ ដោយបានយល់របៀបនេះ ញាតិញោមអាចលះបង់ការប្រកាន់ខ្ជាប់បាន, លះបង់បានដោយមានចិត្តដែលមិនរីករាយឬកើតទុក្ខ តែជាចិត្តចុះសម្រុងជាមួយសង្ខារទាំងឡាយ ដោយបានដឹងធម្មជាតិផ្លាស់ប្តូររបស់

វា តាមគតិបណ្ឌិត។

អនិច្ចា វត សង្ខារា សង្ខារទាំងឡាយមិនទៀងទេ។ បើនិយាយឲ្យងាយយល់ទៅ អនិច្ចំ ភាពមិនទៀងគឺជា ព្រះពុទ្ធ។ បើយើងបានឃើញភាពមិនទៀងយ៉ាងច្បាស់ពិតប្រាកដមែន នោះយើងឃើញថា វាច្បាស់ជាទៀងក្នុងន័យថា ការប្រែប្រួលរបស់វាទៀងទាត់ណាស់។ នេះគឺជា សេចក្តីទៀងទាត់របស់សត្វលោក។ មានការប្រែក្លាយមិនចេះចប់, ពីវ័យកុមារ ទៅវ័យយុវជន ទៅវ័យចាស់ជរា។ ភាពមិនទៀងនេះ វាទៀងទាត់ណាស់ ហើយឥតប្រែប្រួលទេ។ បើញាតិញោមពិនិត្យមើលវាតាមរបៀបនេះ ចិត្តរបស់ញាតិញោមនឹងបានសេចក្តីសុខសាន្ត។ មិនមែនតែញាតិញោមតែម្នាក់ឯងទេ គឺមនុស្សគ្រប់រូបត្រូវតែឆ្លងកាត់តាមផ្លូវនេះទាំងអស់គ្នា។

កាលណាញាតិញោមពិចារណាអំពីអ្វីៗ តាមរបៀបនេះទៅ, ញាតិញោមនឹងបានឃើញថា វាជារបស់មានកង្វល់ រួចហើយសេចក្តីនឿយណាយក៏កើតមានឡើង។ ការពេញចិត្ត សប្បាយរីករាយរបស់ញាតិញោមចំពោះលោកិយនេះ ក៏រលត់បាត់ទៅ។ ញាតិញោមនឹងឃើញថា បើញាតិញោមមានឥវ៉ាន់ច្រើន ញាតិញោមត្រូវចាកចោលរបស់យ៉ាងច្រើន, បើញាតិញោមមានឥវ៉ាន់បន្តិចបន្តួចញាតិញោមក៏ចាកចោលរបស់តិចតួចដែរ។ ទ្រព្យសម្បត្តិគ្រាន់តែជាទ្រព្យសម្បត្តិប៉ុណ្ណោះ, អាយុវែងក៏គ្រាន់តែជាអាយុវែងប៉ុណ្ណោះ; គ្មានអ្វីជាពិសេសទេ។ រឿងសំខាន់គឺយើងត្រូវតែធ្វើតាមការប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ហើយសង់ផ្ទះផ្ទាល់ខ្លួនរបស់យើង, សង់វាតាមរបៀបដែលអាត្មាភាពបានពន្យល់រួចមកហើយ។ សូមញាតិញោមសង់ផ្ទះផ្ទាល់ខ្លួនរបស់ញាតិញោម; សូមលះបង់, លះបង់ទាំងអស់ រហូតទាល់តែចិត្តបានសន្តិភាព ដែលគ្មានជាប់ជំពាក់នឹងការធ្វើដំណើរទៅមុខ ទៅក្រោយ ឬក៏នៅនឹងមួយកន្លែងឡើយ។ ការសប្បាយមិនមែនជាផ្ទះរបស់យើងទេ ការឈឺចុកចាប់ក៏មិនមែនជាផ្ទះរបស់យើងដែរ។ ការសប្បាយនិងការឈឺចាប់, ទាំងពីរនេះសុទ្ធតែរសាយ រួចហើយរលាយបាត់ទៅ។

ព្រះបរមគ្រូ ទ្រង់បានឃើញថា សង្ខារទាំងឡាយមិនទៀងទេ។ អាស្រ័យហេតុនេះ ព្រះអង្គទ្រង់បានបង្រៀនយើងឲ្យលះបង់ចោលនូវការជាប់ជំពាក់ចិត្តលើវាចេញ។ ទោះយ៉ាងណាក៏ដោយ កាលណាយើងអស់អាយុទៅ យើងគ្មានការជ្រើសរើសទេ, យើងមិនអាចយករបស់អ្វីទៅជាមួយបានឡើយ។ ដូច្នេះ ជាការប្រសើរ គួរលះបង់វាមុនពេលស្លាប់ឲ្យហើយទៅ។ វាគ្រាន់តែជាបន្ទុកមួយយ៉ាងធ្ងន់ ក្នុងការធ្វើដំណើរតែប៉ុណ្ណោះ។ ហេតុអ្វីក៏មិនទម្លាក់វាចោលឥឡូវនេះទៅ? ហេតុអ្វីក៏ខំអូសទាញវាយកទៅជាមួយ? សូមលះបង់វាទៅ សូមសម្រាកកាយ ហើយទុកឱកាសឲ្យគ្រួសារញាតិញោមមើលថែរក្សាខ្លួនញាតិញោមផង។

អ្នកទាំងឡាយ ដែលព្យាបាលមើលអ្នកជំងឺ បានធ្វើឲ្យសប្បុរសធម៌និងសីលធម៌របស់ខ្លួនបានរីកចម្រើនឡើង។ អ្នកដែលមានជំងឺ ហើយបានផ្តល់ឱកាសនេះឲ្យអ្នកដទៃ មិនត្រូវធ្វើឲ្យអ្នកព្យាបាលពិបាកឡើយ។ បើមានការឈឺចុកចាប់ ឬមានបញ្ហា ឬមានអ្វីទៀតក្តី, សូមប្រាប់អ្នកព្យាបាលឲ្យបានដឹង ហើយរក្សាចិត្តឲ្យនៅល្អស្អាត។ កូនដែលព្យាបាលមាតាបិតា ត្រូវតែមានចិត្តពោរពេញដោយការ

កក់ក្ដៅនិងសប្បុរសធម៌, មិនត្រូវមានការស្អប់ខ្ពើមទេ។ នេះគឺជាឱសថតែមួយគត់ ដែលអ្នកអាចសង បំណុលដែលអ្នកជំពាក់គាត់បាន។ តាំងពីអ្នកកើតឡើង មានវ័យកុមាររហូតដល់បានពេញវ័យ, អ្នក បានពឹងពាក់អាស្រ័យលើមាតាបិតារបស់អ្នក។ យើងបានរស់នៅដល់សព្វថ្ងៃនេះ គឺដោយសារតែ មាតាបិតាបានជួយថែរក្សាយើងគ្រប់ប្រការ។ យើងជំពាក់គុណគាត់ច្រើនឥតគណនា។

ដូច្នេះ ថ្ងៃនេះលោកអ្នកទាំងឡាយ ដែលជាកូននិងក្រុមញាតិ បានមកជួបជុំគ្នាក្នុងទីនេះ បាន ឃើញរបៀបដែលមាតាបិតារបស់លោកអ្នក បានក្លាយទៅជាកូនរបស់លោកអ្នកវិញហើយ។ កាលពី មុន លោកអ្នកទាំងឡាយជាកូនរបស់គាត់, ឥឡូវនេះ គាត់បានក្លាយទៅជាកូនរបស់លោកអ្នកវិញ ហើយ។ គាត់ចេះតែចាស់ជរាទៅៗ រហូតទាល់តែគាត់ក្លាយទៅជាកូនក្មេងវិញ។ ស្មារតីរបស់គាត់ ភ្លេចភ្លាំងច្រើន, ភ្នែកគាត់មើលមិនសូវឃើញ ហើយត្រចៀកគាត់ស្ដាប់មិនឮ, ជូនកាលគាត់និយាយ ផ្ដេសផ្ដាស រវើរវាយ។ សូមកុំបណ្ដោយឲ្យរឿងទាំងអស់នេះ ធ្វើឲ្យលោកអ្នកមួម៉ៅក្ដៅចិត្ត។ លោក អ្នកទាំងអស់គ្នាដែលព្យាបាលអ្នកជំងឺ ត្រូវតែចេះអត់អធ្យាស្រ័យ។ សូមកុំយកចិត្តទុកដាក់នឹងរឿង ទាំងនេះ, សូមអត់អធ្យាស្រ័យ ហើយបណ្ដោយឲ្យវាប្រព្រឹត្តទៅតាមសម្រួលរបស់វា។ កាលណាកូន ក្មេងមិនព្រមធ្វើតាមពាក្យទូន្មាន, ជួនកាល មាតាបិតាបណ្ដោយឲ្យធ្វើតាមចិត្តវា ដើម្បីគ្រាន់តែរក្សា សន្តិភាព ដើម្បីឲ្យវាសប្បាយចិត្ត។ ឥឡូវនេះ មាតាបិតារបស់លោកអ្នក ដូចជាក្មេងតូចនោះដែរ។ ស្មារតីនិងការរិះគិតរបស់គាត់ ច្រឡូកច្រឡំគ្នាអស់ហើយ។ ជួនកាល គាត់ច្រឡំឈ្មោះរបស់លោក អ្នក ឬក៏លោកអ្នកសុំឲ្យហុចពែង គាត់ទៅហុចចានមកវិញ។ នេះជាការធម្មតាទេ សូមកុំមួម៉ៅ ដោយសាររឿងនេះ។

សូមអ្នកជំងឺដែលបានទទួលការព្យាបាលនោះ នឹកដល់សេចក្ដីសប្បុរសរបស់អ្នកព្យាបាល ហើយខំប្រឹងទ្រាំនឹងការឈឺចុកចាប់ទាំងឡាយ។ សូមខំតាំងចិត្តឲ្យរឹងប៉ឹង, សូមកុំបណ្ដោយឲ្យចិត្ត រាយមាយ ហើយក្រហល់ក្រហាយ និងសូមកុំធ្វើឲ្យអ្នកព្យាបាលពិបាក។ សូមលោកអ្នកទាំងឡាយ ដែលព្យាបាលអ្នកជំងឺ ធ្វើចិត្តរបស់ខ្លួនឲ្យពោរពេញទៅដោយសីលធម៌និងសេចក្ដីសប្បុរស។ សូមកុំ ស្អប់ខ្ពើមចំពោះផ្នែកមិនជាទីគាប់ចិត្តនៃមុខងាររបស់ខ្លួន ដូចជាការជុះលាងខ្ទុះនិងស្លេស្ម ឬទឹកនោម និងអាចម៍ជាដើម។ សូមខិតខំធ្វើឲ្យបានយ៉ាងប្រសើរ។ សមាជិកក្រុមគ្រួសារគ្រប់រូប ជួយសម្រាល បន្ទុកគ្នា។

លោកអ្នកមានតែមាតាបិតាពីរនាក់នោះទេ។ គាត់បានបង្កើតលោកអ្នកមក; គាត់បានធ្វើជាគ្រូ បង្រៀនរបស់លោកអ្នក, ជាអ្នកព្យាបាល, និងជាវេជ្ជបណ្ឌិតរបស់លោកអ្នក; គាត់បានធ្វើអ្វីៗគ្រប់មុខ ទាំងអស់ឲ្យលោកអ្នក។ ការដែលគាត់បានចិញ្ចឹមបីបាច់ថែរក្សាលោកអ្នក បង្ហាត់បង្រៀនលោកអ្នក ចែកទ្រព្យសម្បត្តិឲ្យលោកអ្នក ហើយទុកលោកអ្នកជាអ្នកតវង្សត្រកូលតទៅ, ជាគុណូបការៈយ៉ាងធំ របស់មាតាបិតា។ ដោយហេតុនេះហើយ ទើបព្រះសម្មាសម្ពុទ្ធទ្រង់បានបង្រៀនធម៌កតញ្ញូនិងកតវេទី ការដឹងគុណនិងការខិតខំតបស្នងសងគុណចំពោះមាតាបិតា។ ធម៌ទាំងពីរយ៉ាងនេះ ជួយបំពេញគ្នា ទៅវិញទៅមក; បើមាតាបិតារបស់លោកអ្នក មានការខ្វះខាត ឬមិនសូវមានសុខភាពល្អ ឬក៏មានការ

លំបាក ពេលនោះយើងខិតខំជួយគាត់ពេញទំហឹង តាមសមត្ថភាព។ នេះហៅថា កតញ្ញូកតវេទី; នេះជាសីលធម៌ដែលទ្រទ្រង់លោក។ កតញ្ញូកតវេទី ធ្វើឲ្យគ្រួសារចៀសវាងការបាក់បែកគ្នាបាន ធ្វើឲ្យគ្រួសារមានស្នេហភាពនិងសុខដុមរមនា។

ថ្ងៃនេះ អាត្មាភាពបាននាំយកព្រះធម៌មកធ្វើជាទានចំពោះញាតិញោម នៅពេលដែលញាតិញោមមានជំងឺនេះ។ អាត្មាភាពគ្មានឥវ៉ាន់អ្វីមកជូនញាតិញោមទេ; នៅក្នុងផ្ទះនេះ ហាក់ដូចជាមានឥវ៉ាន់យ៉ាងសម្បូរណ៌ទៅហើយ; ហេតុនេះ អាត្មាភាពជូនព្រះធម៌ចំពោះញាតិញោម គឺជារបស់ដែលមានតម្លៃស្ថិតស្ថេរយូរអង្វែង, ជារបស់មួយដែលញាតិញោមប្រើប្រាស់មិនចេះអស់។ ក្រោយពីទទួលបានធម៌ពីអាត្មាភាពហើយ ញាតិញោមអាចចែករំលែកឲ្យទៅអ្នកឯទៀតទាំងឡាយបានតាមចិត្ត ហើយព្រះធម៌មិនចេះអស់ទេ។ អាត្មាភាពត្រេកអរណាស់ ដោយមានឱកាសធ្វើទានព្រះធម៌ ជូនចំពោះញាតិញោម ហើយអាត្មាភាពសង្ឃឹមថា ព្រះធម៌នឹងធ្វើឲ្យញាតិញោមមានកម្លាំង ដើម្បីទប់ទល់នឹងការឈឺចុកចាប់នេះ។

SMISIS



## ព្រះអាចារ្យ ឆា

ផ្ទះពិតប្រាកដរបស់យើងគឺ **សន្តិភាពនៅខាងក្នុង**។ ផ្ទះដែលជារបស់ខាងក្រៅ អាចល្អស្អាតពិតមែនហើយ តែវាមិនសូវមានសន្តិភាពទេ។ វាចេះតែមានកង្វល់យ៉ាងនេះ រួចហើយយ៉ាងនោះ, សេចក្តីព្រួយបារម្ភយ៉ាងនេះ រួចហើយយ៉ាងនោះទៀត។ ដូច្នេះ យើងនិយាយថា វាមិនមែនជាផ្ទះពិតប្រាកដរបស់យើងទេ, វាជារបស់ក្រៅខ្លួនយើង; ទោះយូរឬឆាប់ យើងនឹងត្រូវតែលះបង់វាចោល។ មិនមែនជាទីកន្លែងដែលយើងអាចរស់នៅរហូតបានទេ ពីព្រោះវាមិនមែនជារបស់យើងពិតប្រាកដ វាជាផ្នែកមួយនៃលោក។